ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

រាជរដ្ឋាភិបាល

*Royal Government*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

**Statement of the Royal Government**

The Royal Government wishes to inform our compatriots and the international public that on 15 July 2014 several elected parliamentary candidates of the Cambodia National Rescue Party led an illegal and disorderly demonstration, attempting to march into Democracy Park under the slogan "Free Democracy Park", and used extreme violence, injuring 38 security guards of the local authorities, of whom 22 were seriously injured and 3 are in intensive care.

The savage violence and serious human rights violations were committed near Democracy Park by demonstrators acting illegally under the leadership of elected CNRP parliamentary candidates and its activists. This violence went well beyond freedom of speech into violation of criminal law through commission of serious premeditated acts, including preparing cement-filled pipes and other objects to use as weapons with intent to murder security guards of the local authority.

The Royal Government, having the responsibility to maintain security and social order, is obliged to take firm legal measures against those responsible for the crimes, within the framework of democracy, rule of law and respect for human rights. These firm and decisive measures are taken in order to maintain public order and national security, to bring justice to the victims and to safeguard the general public. The Royal Government requests the local authorities to continue a thorough investigation in compliance with the law to identify the perpetrators and their accomplices and bring them to justice.

The Royal Government condemns the savage violence, which seriously violated the law and caused social unrest, and which was led, directed and instigated by several elected CNRP parliamentary candidates. The Royal Government appeals to our compatriots to continue cooperating with the Royal Government to maintain safety, public order and the security and dignity of our nation.

Phnom Penh, 16 July 2014

*Unofficial translation*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ**...៣៨...សជណ៧

# សេចក្ដីថ្លែងការណ៍

រាជរដ្ឋាភិបាលសូមជម្រាបជូន ជនរួមជាតិ និងអន្តរជាតិ មេត្តាជ្រាបថា នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិមួយចំនួនបាន ដឹកនាំធ្វើបាតុកម្មដោយខុសច្បាប់យ៉ាងអនាធិបតេយ្យ ដើម្បីសម្រុកចូលទីលានប្រជាធិបតេយ្យក្រោម ពាក្យស្លោក «ដោះលែងទីលានប្រជាធិបតេយ្យ» ដោយប្រើអំពើហិង្សាដ៏កាចសាហាវ បានបណ្ដាលឱ្យ កងកម្លាំងរក្សាសន្តិសុខរបស់អាជ្ញាធរមូលដ្ឋាន ចំនួន ៣៨នាក់ រងរបួស ក្នុងនោះ ២២នាក់ របួសធ្ងន់ និង៣នាក់ស្ថិតនៅក្នុងការសង្គ្រោះបន្ទាន់។

អំពើហិង្សាដ៏ឃោរឃៅ ព្រៃផ្សៃ អមនុស្សធម៌ និងរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ នៅជិត ទីលានប្រជាធិបតេយ្យ បង្កឡើងដោយក្រុមជនដែលមកធ្វើបាតុកម្មដោយខុសច្បាប់ ក្រោមការបញ្ជា និងដឹកនាំដោយបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ និងសកម្មជនរបស់ ខ្លួន។ អំពើហិង្សានេះបានឈានហួសពីការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ក្លាយទៅជា អំពើហិង្សារំលោភច្បាប់ព្រហ្មទណ្ឌជាធរមាន គឺប្រព្រឹត្តអំពើឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ ដែលមានការគ្រោងទុក ជាមុន តាមរយៈការរៀបចំនិងប្រើប្រាស់នូវដំបង ដុំថ្ម និងឧបករណ៍ផ្សេងៗទៀត សម្រាប់ធ្វើជាអាវុធ ក្នុងចេតនាគិតទុកជាមុន ប៉ុនប៉ងមនុស្សឃាតមកលើកងកម្លាំងសន្តិសុខរបស់អាជ្ញាធរមូលដ្ឋាន។

ក្នុងឋានៈជាអ្នកគ្រប់គ្រងរដ្ឋ ដែលមានតួនាទីក្នុងការរក្សាសន្តិសុខនិងសណ្ដាប់ធ្នាប់សង្គម រាជរដ្ឋាភិបាលមានកាតព្វកិច្ចចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ក្នុងក្របខ័ណ្ឌលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ

ការគោរពសិទ្ធិមនុស្ស និងការគោរពច្បាប់ ដើម្បីនាំយកជនទទួលខុសត្រូវចំពោះការប្រព្រឹត្តបទឧក្រិដ្ឋនេះមកផ្តន្ទាទោសតាមផ្លូវច្បាប់។ វិធានការយ៉ាងម៉ឺងម៉ាត់និងហ្មត់ចត់របស់រាជរដ្ឋាភិបាល គឺធ្វើឡើងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ក៏ដូចជាការពារសុវត្ថិភាពរបស់ប្រជាពលរដ្ឋទូទៅ។ រាជរដ្ឋាភិបាលស្នើឱ្យអាជ្ញាធរមានសមត្ថកិច្ច បន្តធ្វើការស្រាវជ្រាវឱ្យបានម៉ឺងម៉ាត់និងស្របតាមនីតិវិធីជាធរមាន រកចាប់ជនដៃដល់ និងមេខ្លោង ដើម្បីយកជនទាំងនោះមកទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

រាជរដ្ឋាភិបាលថ្កោលទោសចំពោះការប្រព្រឹត្តអំពើហិង្សាយ៉ាងឃោរឃៅ ដែលបានរំលោភបំពានច្បាប់យ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលឱ្យមានចលាចលសង្គម ដឹកនាំនិងបញ្ជាដោយបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតមួយចំនួនរបស់គណបក្សសង្គ្រោះជាតិដែលជាមេគំនិត និងសូមអំពាវនាវដល់បងប្អូនជនរួមជាតិបន្តចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម ដើម្បីសេចក្តីថ្លៃថ្នូររបស់ជាតិយើង។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤